# តម្រូវការសម្រាប់អ្នកស្ម័គ្រចិត្ត
# សំណួរដែលគេឧស្សាហ៍សួរ

**តើអ្នកណាត្រូវការ ការត្រួតពិនិត្យប្រវត្តិរូប (clearances)?**

មនុស្សពេញវ័យទាំងអស់ ដែលដាក់ពាក្យសុំធ្វើការ ឬកាន់មុខនាទី ដែលឥតប្រាក់ខែ ជាអ្នកស្ម័គ្រចិត្តនៅកន្លែងមើលក្មេង សាលា ឬកម្មវិធី សកម្មភាព ឬការបម្រើ ដែលទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេង ឬស្ម័គ្រចិត្តធ្វើការជាមួយក្មេង លោកអ្នកត្រូវការ ការត្រួតពិនិត្យប្រវត្តិរូប។

បើសិនជាលោកអ្នកត្រូវបានគេយល់ព្រមឲ្យធ្វើជាអ្នកស្ម័គ្រចិត្ត មុនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ហើយគ្មាន ការបញ្ជាក់ប្រវត្តិរូប (ដោយសារពេលនោះគេមិនតម្រូវឲ្យមាន ការត្រួតពិនិត្យប្រវត្តិរូប) លោកអ្នកមានពេលរហូតដល់ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីសុំការត្រួតពិនិត្យប្រវត្តិរូប របស់លោកអ្នក។

បើសិនជា ការបញ្ជាក់ប្រវត្តិរូប របស់លោកអ្នកមានរយៈពេលលើសពី៦០ខែ លោកអ្នកក៏មានពេលរហូតដល់ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីសុំការត្រួតពិនិត្យប្រវត្តិរូបថ្មី របស់លោកអ្នក ដែរ។

ឧទាហរណ៍នៃមុខនាទីជាអ្នកស្ម័គ្រចិត្តដែលឥតប្រាក់ខែ ដែលទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេង ឬធ្វើការជាមួយក្មេង អាចរួមមាន តែគ្មានកំណត់ទៅនឹង៖

- មាតាបិតា/អាណាព្យាបាល ដែលជួយមើលខុសត្រូវលើក្មេងឲ្យសាលា/Parent/Guardian chaperones for schools
- ក្រុមកុមារឈានមុខស្រី/ក្រុមកុមារឈានមុខប្រុស/Girl Scouts/Boy Scouts
- អ្នកស្ម័គ្រចិត្តរបស់អង្គការដែលជួយផ្នែកយានជំនិះ ឬការបម្រើផ្សេងៗ/Agency volunteers that help with transportation or other services
- អង្គការ Big Brothers (បងប្រុស)/Big Sisters (បងស្រី)
- កម្មវិធីអក្សរសាស្ត្រ/Literacy programs
- ក្រុមកីឡាយុវវ័យ/Little League
- គ្រូបង្វាត់កីឡា/Coaches
- គ្រូបង្រៀននៅវិហារសាសនានៅថ្ងៃអាទិត្យ អ្នកចាត់ចែងកម្មវិធីសម្រាប់ក្មេង/Church Sunday school teachers, child event coordinators
- អ្នកស្ម័គ្រចិត្តធ្វើការជាមួយក្មេងនៅមន្ទីរពេទ្យ/Hospital volunteers working with children

**កំណត់សម្គាល់៖** បញ្ជីខាងលើនេះ **មិនបាន**រៀបរាប់ឲ្យអស់អំពីអ្នកស្ម័គ្រចិត្តនោះទេ។ សូមធ្វើតាមការណែនាំខាងក្រោមនេះ ដើម្បីឲ្យដឹងថាតើអ្នកស្ម័គ្រចិត្តត្រូវគេតម្រូវឲ្យយកលិខិតបញ្ជាក់ ឬអត់៖

ដើម្បីសម្រេចថាតើអ្នកណាដែលនៅអង្គការរបស់លោកអ្នក ត្រូវគេតម្រូវឲ្យមានការត្រួតពិនិត្យប្រវត្តិរូប ឬ អត់ ដើម្បីធ្វើជាអ្នកស្ម័គ្រចិត្តធ្វើការជាមួយក្មេង ជាដំបូង លោកអ្នកត្រូវតែបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំគឺជាមនុស្សពេញវ័យ ពីព្រោះមានតែអ្នកស្ម័គ្រចិត្តដែលជាមនុស្សពេញវ័យទេ ទើបគេតម្រូវឲ្យមានការត្រួតពិនិត្យប្រវត្តិរូប។

បន្ទាប់មក លោកអ្នកគប្បីពិចារណាដោយប្រុងប្រយ័ត្ន ថាតើអ្នកស្ម័គ្រចិត្តនេះជាអ្នកទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេង ឬស្ម័គ្រចិត្តធ្វើការជាមួយក្មេងផ្ទាល់ ឬអត់។

នៅពេលសម្រេច ថាតើអ្នកស្ម័គ្រចិត្តនេះជាអ្នកទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេងឬអត់ សូមពិចារណា ថាតើអ្នកស្ម័គ្រចិត្តធ្វើជាអ្នកជំនួស ឲ្យមាតាបិតា ឬក្នុងនាមជាមាតាបិតា។ បើសិនជាពួកគេធ្វើជាអ្នកជំនួសឲ្យមាតាបិតា ឬក្នុងនាមជាមាតាបិតា ពួកគេត្រូវការ ការពិនិត្យប្រវត្តិរូប។ បើសិនជាមានការសម្រេចថា អ្នកស្ម័គ្រចិត្តមិនមែនជាអ្នកទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេងទេ បន្ទាប់មកលោកអ្នកត្រូវធ្វើតាមវិធីទីពីរសម្រាប់ការពិចារណា ថាតើពួកគេធ្វើការជាមួយក្មេងផ្ទាល់ ឬអត់។

វិធីទីពីរសម្រាប់ការពិចារណា ថាតើអ្នកស្ម័គ្រចិត្តធ្វើការជាមួយក្មេងផ្ទាល់ឬអត់ ដោយសារពួកគេផ្តល់ ការមើលថែ ការមើលខុសត្រូវ ការណែនាំ ឬការគ្រប់គ្រងក្មេង ហើយមានសកម្មភាពទាក់ទងជាមួយក្មេងជាប្រចាំ។ ដោយសារច្បាប់នេះមិនបានឲ្យនិយមន័យលើពាក្យ ការមើលថែ ការមើលខុសត្រូវ ការណែនាំ ឬការគ្រប់គ្រង យើងខ្ញុំសំណូមពរឲ្យប្រើអត្ថន័យទូទៅនៃពាក្យទាំងនេះ ដោយគិតពីសុវត្ថិភាពរបស់ក្មេងជាសំខាន់។ បើសិនជាចម្លើយទៅនឹងសំណួរនេះ ថាពួកគេផ្តល់ ការមើលថែ ការមើលខុសត្រូវ ការណែនាំ ឬការគ្រប់គ្រងក្មេង ពួកគេត្រូវការ ការពិនិត្យប្រវត្តិរូប ប៉ុន្តែបើសិនជាលោកអ្នកសម្រេចថាពួកគេមិនផ្តល់ ការមើលថែ ការមើលខុសត្រូវ ការណែនាំ ឬការគ្រប់គ្រងក្មេងទេ បន្ទាប់មកលោកអ្នកត្រូវតែពិចារណា ថាតើពួកគេមានសកម្មភាពទាក់ទងជាមួយក្មេងជាប្រចាំ ឬអត់។

ចំពោះការមានសកម្មភាពទាក់ទងជាមួយក្មេងជាប្រចាំ គឺត្រូវពិចារណាពីមុខនាទីរបស់អ្នកស្ម័គ្រចិត្តនៅក្នុងអង្គការនោះ។ តើការធ្វើការជាមួយក្មេងជាធម្មតា ឬជាប្រចាំ គឺជាកិច្ចការសំខាន់ចំពោះការទទួលខុសត្រូវជាអ្នកស្ម័គ្រចិត្តរបស់ពួកគេឬទេ?

បើសិនជាលោកអ្នកសម្រេចថា ពួកគេធ្វើការផ្ទាល់ជាមួយក្មេង ពួកគេត្រូវការ ការពិនិត្យប្រវត្តិរូប។ ប៉ុន្តែបើសិនជាលោកអ្នកសម្រេចថា ពួកគេមិនធ្វើការផ្ទាល់ជាមួយក្មេងទេ គេមិនត្រូវការ ការពិនិត្យប្រវត្តិរូប នោះទេ។ សូមពិគ្រោះជាមួយ ការិយាល័យទំនាក់ទំនងជាមួយ ក្រុមគ្រួសារ និងសហគមន៍ ឬការិយាល័យផ្នែក សិទ្ធិ និងការទទួលខុសត្រូវរបស់សិស្ស បើសិនជាលោកអ្នកមានសំណួរអ្វី។

**តើមានការលើកលែងអ្វីដែរ ចំពោះការតម្រូវឲ្យមាន ការពិនិត្យប្រវត្តិរូប សម្រាប់សិស្សានុសិស្សដែលស្ម័គ្រចិត្ត?**

មាន សិស្សានុសិស្សដែលស្ម័គ្រចិត្ត គេមិនតម្រូវឲ្យមាន ការពិនិត្យប្រវត្តិរូបទេ ឲ្យតែពួកគេមានអ្វីៗតាមតម្រូវការ ដូចខាងក្រោមនេះ៖

- ជាបុគ្គលដែលបានចុះឈ្មោះរៀននៅសាលា នាពេលបច្ចុប្បន្ននេះ
- ជាបុគ្គលដែលមិនមែនជាអ្នកទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេង
- ជាបុគ្គលដែលស្ម័គ្រចិត្តជួយក្នុងកម្មវិធីអ្វីមួយនៅក្នុងទីធ្លាសាលា
- កម្មវិធីដែលឧបត្ថម្ភដោយសាលា ដែលបុគ្គលនោះបានចុះឈ្មោះជាសិស្ស និង
- កម្មវិធីដែលមិនមែនសម្រាប់ក្មេងដែលនៅក្រោមការមើលថែរបស់អង្គការមើលថែក្មេង។

**តើក្មេង មានន័យយ៉ាងដូចម្តេច?**

សម្រាប់លិខិតបញ្ជាក់នេះ ក្មេងគឺជាបុគ្គលម្នាក់ដែលមានអាយុក្រោម១៨ឆ្នាំ។

**តើការស្ម័គ្រចិត្តធ្វើការផ្ទាល់ជាមួយក្មេង មានន័យយ៉ាងដូចម្តេច?**

គេបានកំណត់ការស្ម័គ្រចិត្តធ្វើការផ្ទាល់ជាមួយក្មេងថាជា ការមើលថែ ការមើលខុសត្រូវ ការណែនាំ ឬការគ្រប់គ្រងក្មេង និងសកម្មភាពទាក់ទងជាមួយក្មេង ជាប្រចាំធម្មតា។

**តើសកម្មភាពទាក់ទងជាមួយក្មេងជាប្រចាំធម្មតា មានន័យដូចម្តេច?**

សកម្មភាពទាក់ទងជាប្រចាំធម្មតា គឺជាទំនាក់ទំនងធម្មតា និងកើតឡើងដដែលៗ ដែលចាំបាច់សម្រាប់កិច្ចការរបស់បុគ្គល ឬការទទួលខុសត្រូវរបស់អ្នកស្ម័គ្រចិត្ត។

**តើត្រូវការ ការត្រួតពិនិត្យប្រវត្តិរូប អ្វីទៅ?**

អ្នកដែលបម្រុងស្ម័គ្រចិត្តជួយធ្វើការ ត្រូវមានការត្រួតពិនិត្យប្រវត្តិរូប ដូចខាងក្រោមនេះ៖

- របាយការណ៍ អំពីប្រវត្តិទោសព្រហ្មទណ្ឌពីប៉ូលីសរបស់រដ្ឋផិនស៊ីវេនញ៉ា/Report of criminal history from the Pennsylvania State Police (PSP); និង
- របាយការណ៍ពីបទរំលោភបំពានលើកុមារ ពីក្រសួងមនុស្សធម៌-Child Abuse History clearance from the Department of Human Services (Child Abuse)។

ជាបន្ថែមទៀត ត្រូវការ ការផ្តិតម្រាមដៃដែលយោងទៅលើប្រវត្តិបទឧក្រិដ្ឋរបស់រដ្ឋសហព័ន្ធ (FBI) ផ្តល់ឲ្យតាមរយៈប៉ូលីសរដ្ឋធិនស៊ីលវេញ៉ា ឬភ្នាក់ងារដែលមានការអនុញ្ញាតពីប៉ូលីសរដ្ឋធិនស៊ីលវេញ៉ា បើសិនជា៖

- មុខងារដែលអ្នកស្ម័គ្រចិត្តដាក់ពាក្យសុំធ្វើការ គឺបានប្រាក់ខែ និង
- អ្នកស្ម័គ្រចិត្តដែលបានរស់នៅក្រៅរដ្ឋធិនស៊ីលវេញ៉ាអស់រយៈពេល១០ឆ្នាំកន្លងទៅនេះ។

អ្នកស្ម័គ្រចិត្តដែលគេមិនតម្រូវឲ្យមាន ការពិនិត្យប្រវត្តិរូប ពី FBI ដោយសារពួកគេដាក់ពាក្យសុំធ្វើការដែលគ្មានប្រាក់ខែ ហើយបានរស់នៅក្នុងរដ្ឋធិនស៊ីលវេញ៉ាអស់រយៈពេល១០ឆ្នាំកន្លងទៅនេះ ត្រូវស្បថ ឬបញ្ជាក់យ៉ាងច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ថាពួកគេមិនត្រូវបានគេដកសិទ្ធិពីការបម្រើនេះ ដោយផ្អែកទៅលើការផ្តន្ទាទោសនៃបទឧក្រិដ្ឋតាមមាត្រាលេខ §6344 នោះទេ។

**កំណត់សម្គាល់៖** បើសិនជាអ្នកស្ម័គ្រចិត្តមិនបានរស់នៅក្នុងរដ្ឋធិនស៊ីលវេញ៉ាក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះទេ ប៉ុន្តែបានទទួល ការត្រួតពិនិត្យប្រវត្តិរូបពី **FBI** របស់ពួកគេនៅពេលណាមួយ ចាប់តាំងពីបានរស់នៅក្នុងរដ្ឋនេះ ពួកគេត្រូវតែផ្តល់ ការពិនិត្យប្រវត្តិរូប មួយច្បាប់ ទៅឲ្យអ្នកទទួលខុសត្រូវ សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្ត ហើយពួកគេមិនតម្រូវឲ្យមាន ការពិនិត្យប្រវត្តិរូប ពី **FBI** បន្ថែមទៀតទេ។

| **ឧទាហរណ៍នៃអ្នកស្ម័គ្រចិត្ត (មានសកម្មភាពជាធម្មតា ធ្វើការជាមួយក្មេង ឬទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេង។ ត្រូវការ ការត្រួតពិនិត្យប្រវត្តិរូប)** | **ឧទាហរណ៍នៃភ្ញៀវ (គ្មានសកម្មភាពជាធម្មតា មិនធ្វើការជាមួយក្មេង ឬមិនទទួលខុសត្រូវលើសុខមាលភាពរបស់ក្មេង។ មិនត្រូវការ ការពិនិត្យប្រវត្តិរូប ទេ)** |
|---|---|
| • មាតាបិតា/អាណាព្យាបាល ដែលជួយមើលខុសត្រូវលើក្មេងឲ្យសាលា/Parent/Guardian chaperones for schools<br>• ក្រុមកុមារឈានមុខស្រី/ក្រុមកុមារឈានមុខប្រុស/Girl Scouts/ Boy Scouts<br>• អង្គការ Big Brothers (បងប្រុស)/Big Sisters (បងស្រី)<br>• កម្មវិធីអក្សរសាស្ត្រ/Literacy programs<br>• ក្រុមកីឡា សម្រាប់យុវវ័យ/Little League<br>• គ្រូបង្ហាត់កីឡា/Coaches | • ជួយលក់នំដើម្បីរអង្គាសលុយឲ្យសាលា/Helping with a bake sale<br>• វាគ្មិនក្នុងថ្ងៃអាជីព/Career day speakers<br>• វាគ្មិននៃអង្គប្រជុំ/Assembly presenters<br>• ជួយលក់របស់របរដើម្បីអង្គាសលុយឲ្យសាលា/Helping with a school garage sale |

**ខ្ញុំបានស្ម័គ្រចិត្តរួចហើយ។ តើពេលណាទើបខ្ញុំត្រូវសុំ ការពិនិត្យប្រវត្តិរូប ដែលគេតម្រូវ?**

បើសិនជាលោកអ្នកត្រូវបានគេយល់ព្រមឲ្យធ្វើជាអ្នកស្ម័គ្រចិត្តមុនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ហើយគ្មាន ការពិនិត្យប្រវត្តិរូប នៅឡើយ (ដោយសារពីមុនគេមិនបានតម្រូវឲ្យលោកអ្នកសុំ ការពិនិត្យប្រវត្តិរូប នេះ) លោកអ្នកមានពេលរហូតដល់ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីសុំ ការពិនិត្យប្រវត្តិរូប របស់លោកអ្នក។

បើសិនជាលោកអ្នកត្រូវបានគេយល់ព្រមឲ្យធ្វើជាអ្នកស្ម័គ្រចិត្តមុនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ហើយមាន ការពិនិត្យប្រវត្តិរូប រួចហើយ ដោយសារអង្គការរបស់លោកអ្នកតម្រូវឲ្យលោកអ្នកសុំ ការពិនិត្យប្រវត្តិរូប មួយ ឬទាំងអស់ ហើយការពិនិត្យប្រវត្តិរូបរបស់លោកអ្នក លើសពី៦០ខែ លោកអ្នកក៏មានពេលរហូតដល់ ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ ដើម្បីសុំ ការពិនិត្យប្រវត្តិរូប របស់លោកអ្នក ដែរ។

បើសិនជាលោកអ្នកត្រូវបានគេយល់ព្រមឲ្យធ្វើជាអ្នកស្ម័គ្រចិត្តមុនថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ហើយមានការពិនិត្យប្រវត្តិរូប រួចហើយ ដោយសារអង្គការរបស់លោកអ្នកតម្រូវឲ្យលោកអ្នកសុំការពិនិត្យប្រវត្តិរូប មួយ ឬទាំងអស់ ហើយការពិនិត្យប្រវត្តិរូបរបស់លោកអ្នក តិចជាង៦០ខែ លោកអ្នកមានពេលរហូតដល់៦០ខែ ចាប់ពីថ្ងៃនៃការពិនិត្យប្រវត្តិរូបចាស់របស់លោកអ្នក ដើម្បីសុំការពិនិត្យប្រវត្តិរូបថ្មី របស់លោកអ្នក ហើយយកការពិនិត្យប្រវត្តិរូបណាមួយដែលគេតម្រូវឲ្យយកឥឡូវនេះ ដែលគេមិនបានតម្រូវឲ្យយកកាលពីមុន (ឧ. បើសិនជាអង្គការរបស់លោកអ្នកតម្រូវឲ្យមាន ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង (Child Abuse clearance) ប៉ុន្តែមិនមែនជាការពិនិត្យប្រវត្តិរូប តាមរយៈ ប៉ូលីសរដ្ឋធិនស៊ីលវេញ៉ា (PSP) នៅពេលដែល Child Abuse clearance របស់លោកអ្នកផុតកំណត់ យោងទៅលើកំឡុងពេល៦០ខែ លោកអ្នកត្រូវបន្ថែមការពិនិត្យប្រវត្តិរូបផ្សេងទៀតណាមួយដែលគេបានតម្រូវមាន)។

**តើមានការតម្រូវអ្វីដែលអ្នកស្ម័គ្រចិត្តអាចសុំ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង និងការពិនិត្យប្រវត្តិរូប ពី PSP ដោយឥតបង់ថ្លៃ ដែរឬទេ?**

មាន។ ដើម្បីឲ្យគេលើកលែងថ្លៃសម្រាប់ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង និងការពិនិត្យប្រវត្តិរូប ពី PSP ត្រូវមានលក្ខណៈដូចតទៅ៖

១) ការពិនិត្យប្រវត្តិរូប ត្រូវការសម្រាប់ការស្ម័គ្រចិត្ត។

២) ការពិនិត្យប្រវត្តិរូប មិនអាចប្រើសម្រាប់ការងារដែលបានប្រាក់ខែ ឬសម្រាប់គោលបំណងផ្សេងទៀតបានទេ។

៣) ការពិនិត្យប្រវត្តិរូប ត្រូវផ្តល់ឲ្យអ្នកស្ម័គ្រចិត្តដោយឥតគិតថ្លៃ តែ៥៧ខែម្តងប៉ុណ្ណោះ។

៤) អ្នកស្ម័គ្រចិត្តត្រូវស្បថ ឬបញ្ជាក់យ៉ាងច្បាស់លាស់ជាលាយលក្ខណ៍អក្សរក្រោមការពិន័យនៃមាត្រាលេខ 18 Pa.C.S. § 4904 (ដែលទាក់ទងនឹងការក្លែងបន្លំដោយគ្មានសម្បថទៅអាជ្ញាធរ) នូវអ្វីៗដូចតទៅ៖

   **(i)** ការពិនិត្យប្រវត្តិរូប ត្រូវការសម្រាប់ការស្ម័គ្រចិត្ត។

   **(ii)** អ្នកស្ម័គ្រចិត្តមិនទាន់បានទទួល ការពិនិត្យប្រវត្តិរូប ដោយឥតបង់ថ្លៃក្នុងកំឡុងពេល៥៧ខែ នៅឡើយ ។

   **(iii)** អ្នកស្ម័គ្រចិត្តដឹងថា ការពិនិត្យប្រវត្តិរូប នឹងគ្មានសុពលភាព ឬប្រើសម្រាប់គោលបំណងអ្វីផ្សេងទៀតបានទេ។

**ខ្ញុំជាអ្នកស្ម័គ្រចិត្តថ្មីៗ ពេលណាទើបខ្ញុំត្រូវសុំការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង (Child Abuse clearance) ដែលគេតម្រូវ?**

ចាប់ផ្តើមនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ អ្នកស្ម័គ្រចិត្តថ្មីទាំងអស់ត្រូវផ្តល់ ការពិនិត្យប្រវត្តិរូប មុនពេលចាប់ផ្តើមធ្វើការងារ។

បើសិនជាគេតម្រូវឲ្យលោកអ្នកមាន ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង ថ្មី ហើយការដាក់ពាក្យស្នើសុំរបស់លោកអ្នក មុនថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ គេនឹងតម្រូវឲ្យលោកអ្នកបង់ប្រាក់ ១០$។

**តើខ្ញុំត្រូវសុំ ការពិនិត្យប្រវត្តិរូបថ្មីរបស់ខ្ញុំ ញឹកញាប់ប៉ុណ្ណា?**

ចាប់ផ្តើមនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ គេនឹងតម្រូវឲ្យអ្នកស្ម័គ្រចិត្តទាំងអស់មាន ការពិនិត្យប្រវត្តិរូប រៀងរាល់៦០ខែ។

ទោះជាយ៉ាងនេះក៏ដោយ បើសិនជាបុគ្គល ឬអង្គការ ជ្រើសរើសយក ការពិនិត្យប្រវត្តិរូបថ្មីទាំងអស់ ក្នុងពេលជាមួយគ្នា គេនឹងប្រើថ្ងៃខែចាស់ដែលមាននៅលើលិខិតបញ្ជាក់ ជាជាងថ្ងៃខែថ្មី សម្រាប់ថ្ងៃខែសុំ ការពិនិត្យប្រវត្តិរូបថ្មី។

**ចាប់ផ្តើមនៅ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥៖**

- ការពិនិត្យប្រវត្តិបទឧក្រិដ្ឋពីប៉ូលីសរដ្ឋផិនស៊ីលវេញ៉ា មានតម្លៃ 0$ / The PSP criminal history clearance costs $0
- លិខិតបញ្ជាក់ពីប្រវត្តិនៃការរំលោភបំពានលើក្មេង មានតម្លៃ 0$ / The Child Abuse certification costs $0
- លិខិតបញ្ជាក់ពីប្រវត្តិនៃបទឧក្រិដ្ឋ ពី FBI រដ្ឋសហព័ន្ធ មានតម្លៃ ២៥,៧៥$ តាមរយៈ ក្រសួងសន្តិសុខជាតិ (DHS) /The FBI federal criminal history certification costs $25.75 through DHS
- លិខិតបញ្ជាក់ពីប្រវត្តិនៃបទឧក្រិដ្ឋ ពី FBI រដ្ឋសហព័ន្ធ មានតម្លៃ ២៥,៧៥$ តាមរយៈ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា (PDE) /The FBI federal criminal history certification costs $27.00 through PDE

**តើ ក្រសួងមនុស្សធម៌ និងក្រសួងអប់រំ បញ្ចុះថ្លៃសម្រាប់ ការពិនិត្យប្រវត្តិរូប ពី FBI ដែរឬទេ?**

មិនចុះថ្លៃទេ។ FBI កំណត់លក្ខណៈចាំបាច់សំខាន់ៗសម្រាប់ថ្លៃឈ្នួលនេះ។ ថ្លៃឈ្នួលដែលនៅសល់ទាំងប៉ុន្មានសម្រាប់ចេញឲ្យថ្លៃចំណាយដោយ DHS, PDE, PSP, អ្នករៀបចំការពិនិត្យប្រវត្តិរូប និងកន្លែងផ្តិតម្រាមដៃ។

**ជាអ្នកស្ម័គ្រចិត្ត តើខ្ញុំសុំ ការពិនិត្យប្រវត្តិនៃបទឧក្រិដ្ឋ ពី FBI របស់ខ្ញុំតាមរយៈ ក្រសួងអប់រំ ឬក្រសួងមនុស្សធម៌?**

ក្រសួងដែលអ្នកដាក់ពាក្យសុំធ្វើការ ត្រូវផ្ញើពាក្យស្នើសុំលិខិតបញ្ជាក់ពី FBI គឺយោងទៅតាមអង្គការ ដែលពួកគេចង់ស្ម័គ្រចិត្តជួយ។

បើសិនជា អ្នកដាក់ពាក្យសុំធ្វើការ ចង់ធ្វើការនៅសាលា ឬក្នុងកម្មវិធីដែលទាក់ទងនឹងសាលា ពួកគេត្រូវដាក់ពាក្យសុំ ការពិនិត្យប្រវត្តិនៃបទឧក្រិដ្ឋពី FBI របស់ពួកគេតាមរយៈ ក្រសួងអប់រំ។

បើសិនជា អ្នកដាក់ពាក្យសុំធ្វើការ ចង់ស្ម័គ្រចិត្តជាមួយក្មេងក្នុងកម្មវិធីអ្វីមួយនៅក្រៅសាលា ឬមុខនាទីដូចជាការជួយ ក្មេងរស់នៅក្នុងផ្ទះជាក្រុម នៅក្នុងវិហារសាសនា ជាគ្រូបង្ហាត់កីឡា បេហ្សបល (Little League) ឬបាល់ទាត់ ។ល។ ពួកគេត្រូវដាក់ពាក្យសុំលិខិតបញ្ជាក់ពី FBI តាមរយៈក្រសួងមនុស្សធម៌។

**ខ្ញុំបានស្នើសុំ ការពិនិត្យមើលប្រវត្តិនៃការរំលោភបំពានលើក្មេង មុនថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥។ តើខ្ញុំអាចទទួលសំណងវិញទេ សម្រាប់ការលើកលែងថ្លៃឈ្នួលនៃ ការពិនិត្យប្រវត្តិរូបនេះ?**

មិនអាចទេ។ គួរឲ្យសោកស្តាយ DHS មិនអាចសងសំណងសម្រាប់ ការបញ្ជាក់ប្រវត្តិនៃការរំលោភបំពានលើក្មេង ដែលបានធ្វើឡើងមុនថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៥ បាន។

**តើនឹងមានវិធីសុំ ការពិនិត្យប្រវត្តិរូប ថ្មី ដែរឬទេ?**

គ្មានទេ។ វិធីសុំការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង និងប្រវត្តិបទឧក្រិដ្ឋ នឹងនៅដដែល។ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង និងបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា នឹងបន្តដាក់ពាក្យសុំ និងបង់ថ្លៃ តាមគ្រឿងអេឡិចត្រូនិច។ នៅពេលបង្ហាញពីគោលបំណងនៃការពិនិត្យប្រវត្តិរូប អ្នកដាក់ពាក្យស្នើសុំនឹងតែត្រូវបញ្ជាក់ប្រាប់ថាជាអ្នកស្ម័គ្រចិត្ត។

ការណែនាំដែលចាំបាច់ និងបណ្តាញតភ្ជាប់ ដើម្បីដាក់ពាក្យស្នើសុំសម្រាប់ការបញ្ជាក់ទាំងអស់ អាចឃើញមាននៅក្នុងវ៉ិបសៃ www.dhs.state.pa.us/findaform/childabusehistoryclearanceforms/index.htm គេនឹងផ្លាស់ប្តូរវ៉ិបសៃរបស់ប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ដើម្បីឲ្យត្រូវតាមការលើកលែងថ្លៃឈ្នួល។ ជាបន្ថែមទៀត លិខិតសម្រាប់បំពេញថ្មីនឹងមានសម្រាប់ការចម្លងយកពីវ៉ិបសៃ។

**តើខ្ញុំអាចប្រើ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង ឬបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ដែលខ្ញុំបានស្នើសុំសម្រាប់សកម្មភាពស្ម័គ្រចិត្តរបស់ខ្ញុំ សម្រាប់ការស្ម័គ្រចិត្តនៅកន្លែងផ្សេងទៀត បានដែរឬទេ?**

អាចបាន។ បុគ្គលណាម្នាក់ដែលបានទទួលការពិនិត្យប្រវត្តិក្នុងកំឡុងពេល៦០ខែកន្លងមកនេះ អាចប្រើលិខិតនេះសម្រាប់ ការស្ម័គ្រចិត្ត កម្មវិធីសកម្មភាព ឬ សម្រាប់ការបម្រើ អ្វីក៏បាន។

**តើខ្ញុំអាចប្រើ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង ឬបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ដែលខ្ញុំបានស្នើសុំសម្រាប់សកម្មភាពស្ម័គ្រចិត្តរបស់ខ្ញុំ សម្រាប់ការសុំធ្វើការងារផ្សេងទៀត បានដែរឬទេ?**

មិនបានទេ។ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង ឬបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ដែលបានទទួលសម្រាប់គោលបំណងនៃការស្ម័គ្រចិត្ត អាចប្រើសម្រាប់តែសកម្មភាពស្ម័គ្រចិត្តតែប៉ុណ្ណោះ។ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង ឬបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ដែលបានទទួលសម្រាប់គោលបំណងនៃការស្ម័គ្រចិត្ត នឹងបញ្ជាក់ថាការពិនិត្យប្រវត្តិរូបនេះ គឺអាចប្រើសម្រាប់តែការស្ម័គ្រចិត្តតែប៉ុណ្ណោះ។

**តើគេទទួលស្គាល់ការប្រើអ្នកទីបីដើម្បីសុំ ការពិនិត្យប្រវត្តិរូប ដែរឬទេ?**

អាចប្រើអ្នកទីបីដើម្បីសុំ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង បទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា និង **FBI** តាមការប្រើវិធីដែលបានចែងខាងលើនេះ។ គេ**មិនអនុញ្ញាត**ឲ្យពួកគេឆែកមើលប្រវត្តិរូប ឬការពិនិត្យមើលប្រវត្តិរូប តាមរយៈកម្មវិធីផ្ទុកទិន្នន័យផ្សេងទៀត ជំនួសវិធីដែលបានចែងដូចខាងលើនេះបានទេ។ ជាបន្ថែមទៀត អ្នកទទួលខុសត្រូវចំពោះការជ្រើសរើសអ្នកស្ម័គ្រចិត្ត នៅតែជាអ្នកទទួលខុសត្រូវចំពោះការជ្រើសរើសយោងទៅលើព័ត៌មានដែលបានទទួល។

**តើខ្ញុំត្រូវតែផ្តល់ច្បាប់ចម្លងនៃ ការពិនិត្យប្រវត្តិបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ឬ FBI របស់ខ្ញុំ នៅពេលខ្ញុំដាក់ពាក្យស្នើសុំ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេងឬទេ?**

ចាប់ផ្តើមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ គេមិនតម្រូវឲ្យអ្នកស្ម័គ្រចិត្តផ្តល់ការពិនិត្យប្រវត្តិបទឧក្រិដ្ឋពីប៉ូលីសនៃរដ្ឋផិនស៊ីលវេញ៉ា ឬ FBI មួយច្បាប់ ជាមួយលិខិតដាក់ពាក្យសុំ ការពិនិត្យប្រវត្តិនៃការរំលោភបំពានលើក្មេង ទេ។ បើសិនជាក្រសួងទទួលច្បាប់ចម្លងនេះភ្ជាប់ជាមួយការពិនិត្យមើលប្រវត្តិនៃការរំលោភបំពានលើក្មេង យើងខ្ញុំនឹងមិនបញ្ជូនច្បាប់ចម្លងទាំងនេះត្រឡប់ទៅវិញទេ ហើយនឹងច្រៀកចោល ដោយសារព័ត៌មានដែលមាននៅក្នុងការពិនិត្យប្រវត្តិរូបនេះ ជាព័ត៌មានដែលត្រូវរក្សាទុកជាសម្ងាត់។

**តើមានការតម្រូវអ្វីផ្សេងទៀតឬទេ?**

បើសិនជាអ្នកស្ម័គ្រចិត្តត្រូវគេចាប់ខ្លួន ឬផ្តន្ទាទោស ដោយបទល្មើសដែលជាមូលដ្ឋាននៃការបដិសេធមិនឲ្យចូលរួមក្នុង កម្មវិធី សកម្មភាព ឬការបម្រើ ឬគេរកឃើញថាមានឈ្មោះជាជនល្មើសច្បាប់ ឬមាននៅក្នុងរបាយការណ៍ អ្នកស្ម័គ្រចិត្តនោះត្រូវផ្តល់ដំណឹងឲ្យ រដ្ឋបាល ឬអ្នកតំណាង របស់ពួកគេ ជាលាយលក្ខណ៍អក្សរ មិនឲ្យហួសពី៧២ម៉ោង ក្រោយពេលគេ ចាប់ខ្លួន ផ្តន្ទាទោស ឬលិខិតជូនដំណឹង ដែលបុគ្គលនោះត្រូវបានគេឲ្យឈ្មោះថាជា ជនល្មើសច្បាប់ នៅក្នុងកន្លែងផ្ទុកទិន្នន័យទូទាំងរដ្ឋ។

អ្នកស្ម័គ្រចិត្តណាដែលមានបំណងលាក់ព័ត៌មាន ដូចបានតម្រូវមកខាងលើនេះ គឺជាការប្រព្រឹត្តបទល្មើសជាមជ្ឈឹមកម្រិតបី ហើយនឹងទទួលការដាក់វិន័យ រហូតដល់ និងរួមទាំង ការដេញចេញ ឬការបដិសេធមិនឲ្យធ្វើជាអ្នកស្ម័គ្រចិត្ត។

**តើការតម្រូវនៃការបញ្ជាក់បណ្តោះអាសន្នសម្រាប់អ្នកស្ម័គ្រចិត្តគឺជាអ្វី?**

«អ្នកស្ម័គ្រចិត្តដែលមិនរស់នៅក្នុងរដ្ឋនេះ» បុគ្គលដែលរស់នៅក្នុងរដ្ឋផ្សេង ឬនៅក្រៅប្រទេស អាចធ្វើជាអ្នកស្ម័គ្រចិត្តក្នុងរយៈពេលមិនលើសពី៣០ថ្ងៃ ក្នុងមួយឆ្នាំ ក្នុងខណៈដែលពួកគេផ្តល់ ការពិនិត្យប្រវត្តិរូបពីរដ្ឋ ឬពីប្រទេស ដែលពួកគេរស់នៅ។ បើសិនជាបុគ្គលនោះនឹងស្ម័គ្រចិត្តជួយរយៈពេល លើសពី៣០ថ្ងៃ ក្នុងមួយឆ្នាំ ពួកគេត្រូវសុំ ការពិនិត្យប្រវត្តិរូប ដូចបានរៀបរាប់ខាងលើនេះត្រង់ចំណុច «តើត្រូវការ ការពិនិត្យប្រវត្តិរូបណាមួយ/ Which clearances are needed.» អ្នកស្ម័គ្រចិត្តដែលរស់នៅក្នុងរដ្ឋផិនស៊ីលវេញ៉ា គ្មានរយៈពេលស្ម័គ្រចិត្តបណ្តោះអាសន្ន ហើយត្រូវសុំ ការពិនិត្យប្រវត្តិរូប ដូចបានរៀបរាប់ខាងលើនេះត្រង់ចំណុច «តើត្រូវការ ការពិនិត្យប្រវត្តិរូបណាមួយ/Which clearances are needed.» អ្នកស្ម័គ្រចិត្តដែលមិនរស់នៅក្នុងរដ្ឋនេះ ត្រូវផ្តល់ឲ្យអ្នកទទួលខុសត្រូវក្នុងការជ្រើសរើសអ្នកស្ម័គ្រចិត្តនូវឯកសារនៃ ការពិនិត្យប្រវត្តិរូបពីរដ្ឋ ឬប្រទេស ដែលខ្លួនរស់នៅ។

**តើអ្នកទទួលខុសត្រូវចំពោះការទទួលអ្នកស្ម័គ្រចិត្ត តម្រូវឲ្យគាត់ទុកច្បាប់ចម្លងនៃ ការពិនិត្យប្រវត្តិរូប របស់ខ្ញុំ ឬយ៉ាងណា?**

ត្រូវទុក។ តាមមាត្រាលេខ § 6344 (b.1) និយោជក រដ្ឋបាល អ្នកគ្រប់គ្រង ឬអ្នកទទួលខុសត្រូវផ្សេងទៀត សម្រាប់ការសម្រេចជួលបុគ្គលិក ឬទទួលបុគ្គលឲ្យធ្វើការអ្វីមួយ ដែលគេតម្រូវឲ្យមាន ការពិនិត្យប្រវត្តិរូប ត្រូវមានព័ត៌មានដែលគេត្រូវការមួយច្បាប់ ហើយតម្រូវឲ្យបុគ្គលផ្តល់ឯកសារ ដែលគេត្រូវការ មុនពេលចូលធ្វើការ ឬមុនពេលទទួលឲ្យធ្វើការអ្វីមួយ លើកលែងតែអ្នកធ្វើការបណ្តោះអាសន្ន ក្នុងរយៈពេលខ្លី ដូចបានរៀបរាប់ក្នុងមាត្រាលេខ § 6344.2 (f) និងចង្អុលបញ្ហាញដូចខាងលើនេះ។ និយោជក រដ្ឋបាល អ្នកគ្រប់គ្រង ឬអ្នកទទួលខុសត្រូវផ្សេងទៀត សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្ត ដែលមិនបានឲ្យអ្នកដាក់ពាក្យផ្តល់ការពិនិត្យប្រវត្តិរូប ដែលគេតម្រូវឲ្យមាន មុនពេលជួលមនុស្សធ្វើការ គឺជាការប្រព្រឹត្តបទល្មើសជាមជ្ឈឹមកម្រិតបី។

គេបានរំឭកអង្គការទាំងអស់ថា ព័ត៌មានអំពីការបញ្ជាក់នៃការរំលោភបំពានលើក្មេង ជាឯកសារសម្ងាត់ ហើយមិនអាចបញ្ជូនទៅឲ្យបុគ្គលដទៃទៀតបានទេ។

**តើអ្នកទទួលខុសត្រូវចំពោះការជ្រើសរើសអ្នកស្ម័គ្រចិត្ត មានអភ័យឯកសិទ្ធិពីការទទួលខុសត្រូវដែលទាក់ទងនឹងវិធីធ្វើការពិនិត្យប្រវត្តិរូប នេះដែរឬទេ?**

មាន។ និយោជក រដ្ឋបាល អ្នកគ្រប់គ្រង ឬអ្នកទទួលខុសត្រូវផ្សេងទៀត សម្រាប់ការជ្រើសរើសអ្នកស្ម័គ្រចិត្ត មានអភ័យឯកសិទ្ធិ ហើយត្រូវបានគេចាត់ទុកថា បានអនុវត្តយ៉ាងស្មោះ នៅពេលជ្រើសរើសបុគ្គលដែលគេតម្រូវឲ្យមាន ការពិនិត្យប្រវត្តិរូប និងរក្សាសំណុំឯកសារទុកតាមការតម្រូវរបស់ច្បាប់។

**តើស្ថាប់ងារ ឬអង្គការ អាចបង្កើតច្បាប់អ្វីបន្ថែមទៀត បានដែរឬទេ?**

អាច គ្មានការហាមឃាត់ដល់ អង្គការណាមួយ ឬ អ្នកទទួលខុសត្រូវណាម្នាក់ ក្នុងការបង្កើតតម្រូវការបន្ថែមទៀតសម្រាប់ កម្មវិធី សកម្មភាព ឬការបម្រើ នោះទេ។

**តើអ្នកស្ម័គ្រចិត្ត ត្រូវគេតម្រូវឲ្យរាយការណ៍ពី ការធ្វើបាប និងការមិនយកចិត្តទុកដាក់ ចំពោះក្មេងដែរឬទេ?**

តម្រូវឲ្យរាយការណ៍។ អ្នកស្ម័គ្រចិត្តទាំងអស់ ត្រូវគេតម្រូវឲ្យរាយការណ៍។ ទោះជាគេមិនតម្រូវឲ្យមានការហ្វឹកហ្វឺនក៏ដោយ ការហ្វឹកហ្វឺនដោយឥតគិតថ្លៃ៣ម៉ោង តាមអ៊ិនធ័រណិត មាននៅក្នុងវិបសៃ www.reportabusepa.pitt.edu